00700584

D11/2/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**Kingdom of Cambodia**
**Nation Religion King**

**Royaume du Cambodge**
**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

---

**លេខសំណុំរឿង: ០០៣/០៧-០៩-២០០៩/អ.វ.ត.ក.--ក.ស.ច.ស.**

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**ឯកសារដើម**
**DOCUMENT RECEIVED/DOCUMENT REÇU**
**ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception):** 26 / 08 / 2011
**ម៉ោង (Time/Heure):** 11 : 05
**មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier:** Uch Arun

| | |
|---|---|
| ចំពោះមុខ ៖ | ចៅក្រម យូ ប៊ុនឡេង |
| | ចៅក្រម Siegfried BLUNK |
| កាលបរិច្ឆេទ ៖ | ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ |
| ភាសា ៖ | អង់គ្លេស |
| ចំណាត់ថ្នាក់ឯកសារ ៖ | [សម្ងាត់] [សាធារណៈ] |

---

## ដីកាសម្រេចលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី
## របស់លោក រ៉ប ហាមីល (Rob Hamill)

---

<u>**សហព្រះរាជអាជ្ញា**</u>

លោកស្រី ជា លាង

លោក Andrew CAYLEY

០០៣/០៧-០៩-២០០៩/អ.វ.ត.ក.--ក.ស.ច.ស. លេខ/No: D11/2/3

យើង **យូ ប៊ុនឡេង** និង Siegfried BLUNK (ស៊ីគហ្វ្រីដ ប្លុង) សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (*"អ.វ.ត.ក."*)

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ (*"ច្បាប់ស្តីពី អ.វ.ត.ក"*)

បានឃើញវិធាន ១២ វិធាន ១២ *ស្ទួន* វិធាន ២១ វិធាន ២៣ វិធាន ២៣ *ស្ទួន* វិធាន ២៣ *ស្ទួនពីរ* វិធាន ៥៣ និង វិធាន ៥៥ នៃវិធានផ្ទៃក្នុងនៃ អ.វ.ត.ក (វិសោធនកម្មលើកទី៧) (*"វិធានផ្ទៃក្នុង"*)

បានឃើញមាត្រា ១ មាត្រា ៣ និងមាត្រា ៦ នៃសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ (*"សេចក្តីណែនាំអនុវត្ត"*)

បានឃើញសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង កាំង ហ្កេកអ៊ាវ *ហៅ* ឌុច (០០១/១៨ កក្កដា ២០០៧/អវតក/អជសដ)

បានឃើញកិច្ចស៊ើបសួរដែលកំពុងដំណើរការទៅតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញា។

## I. **ប្រវត្តិនីតិវិធី**

១. ដីកាសម្រេចនេះទាក់ទិននឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក **រ៉ប ហាមីល** (Rob HAMILL) (*"អ្នកដាក់ពាក្យសុំ"*) ដែលបានដាក់កាលពីថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១១ ជូនសហចៅក្រមស៊ើបអង្កេត (ស.ច.ស) ដោយផ្នែកគាំពារជនរងគ្រោះនៃ អ.វ.ត.ក (*"VSS"*) អនុលោមតាមវិធាន១២*ស្ទួន*(ខ)[១]។

---

[១] សូមមើលអនុស្សរណៈអន្តរការិយាល័យ (សម្ងាត់បំផុត) ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១១។

២. អ្នកដាក់ពាក្យសុំបានស្នើសុំធ្វើជាភាគីនៃដំណើរការនីតិវិធីក្នុងសំណុំរឿង០០៣ និង០០៤ ដោយសារតែព្យសនកម្មដែលគាត់បានទទួលរងដោយសារផលវិបាកដោយផ្ទាល់នៃបទឧក្រិដ្ឋ ដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក[2] បន្ថែមទៅលើការស្លាប់បងប្រុសគាត់ឈ្មោះ ឃែរី មីល (Kerry Mill) ដែលត្រូវបានចាប់ខ្លួននៅឆ្នាំ ១៩៧៨ ដោយកងទ័ពជើងទឹកនៃរបបកម្ពុជាប្រជាធិបតេយ្យ នៅពេលដែលគាត់បានធ្វើដំណើរតាមទូកក្ដោងឈ្មោះ Foxy Lady ចូលមកក្នុងដែនទឹកប្រទេសកម្ពុជា ហើយក្រោយមកត្រូវបានបញ្ជូនទៅមន្ទីរ ស២១ ដើម្បីសួរចម្លើយ និងសម្លាប់។

៣. អ្នកដាក់ពាក្យសុំក៏បានចោទប្រកាន់ផងដែរថា បុគ្គលដែលមានឈ្មោះថា [redacted] ជាអ្នកទទួលខុសត្រូវចំពោះបទឧក្រិដ្ឋទាំងនេះ[3]។

៤. អ្នកដាក់ពាក្យសុំបានស្នើសុំថា ព័ត៌មានដែលគាត់បានដាក់សម្រាប់សំណុំរឿង០០២[4] និង សក្ខីកម្មដែលគាត់បានធ្វើនៅថ្ងៃទី៥៩ នៃសវនាការ[5] សម្រាប់សំណុំរឿង០០១ ត្រូវបញ្ចូលទៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់គាត់សម្រាប់សំណុំរឿង០០៣[6]។

---

[2] សូមមើលរបាយការណ៍របស់អង្គភាពជនរងគ្រោះស្ដីពីពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីលេខ VSS-2011-009-OCIJ ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១១, ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះលេខ VU 11-VSS-00002 និងឧបសម្ព័ន្ធ ចុះថ្ងៃទី ៧ ខែ មេសា ឆ្នាំ ២០១១ ទំព័រ១-៤ និង៧។

[3] សូមមើលរបាយការណ៍របស់អង្គភាពជនរងគ្រោះស្ដីពីពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីលេខ VSS-2011-009-OCIJ ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១១, ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះលេខ VU 11-VSS-00002 និងឧបសម្ព័ន្ធ ចុះថ្ងៃទី ៧ ខែ មេសា ឆ្នាំ ២០១១ ទំព័រ១-៤ និង៧។

[4] យោងទៅដល់សំណុំរឿង០០២, ឯកសារលេខ D22/2073។

[5] យោងទៅដល់ប្រតិចារឹកសវនាការក្នុងសំណុំរឿង០០១ ឯកសារលេខ E1/63.1។

[6] សូមមើលរបាយការណ៍របស់អង្គភាពជនរងគ្រោះស្ដីពីពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីលេខ VSS-2011-009-OCIJ ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១១, ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះលេខ VU 11-VSS-00002 និងឧបសម្ព័ន្ធ ចុះថ្ងៃទី ៧ ខែ មេសា ឆ្នាំ ២០១១ ទំព័រ១-៤ និង៧។

## II. សំអាងហេតុសម្រាប់ចេញដីកាសម្រេច

៥. ពាក្យសុំនេះត្រូវតែទទួលបានការបដិសេធចោល ដោយសារអ្នកដាក់ពាក្យសុំមិនបានបង្ហាញថា គាត់បានទទួលរងព្យសនកម្មផ្លូវចិត្តដូចបានចោទប្រកាន់ ដែលជាផលវិបាកដោយផ្ទាល់នៃការស្លាប់បងប្រុសគាត់ទេ។

៦. វិធាន២៣*ស្ទួន*(១)(ខ)តម្រូវថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបង្ហាញថា គាត់បានទទួលរងព្យសនកម្មជាផលវិបាកដោយផ្ទាល់នៃបទឧក្រិដ្ឋប្រឆាំងនឹងជនត្រូវចោទ។ បើតាមការប្រើប្រាស់អត្ថន័យជាភាសាអង់គ្លេស[៧] ពាក្យថា "direct" ("ដោយផ្ទាល់") នៅក្នុងបរិបទនេះមានន័យថា បទឧក្រិដ្ឋនោះបណ្តាលឲ្យមានព្យសនកម្មដោយពុំមានទំនាក់ទំនងដោយផ្ទាល់រវាងហេតុ និងបច្ច័យទេ។ ទោះជាយ៉ាងណាក្តី នៅក្នុងករណីនេះ ទំនាក់ទំនងផ្ទាល់ដែលបណ្តាលឲ្យមានព្យសនកម្មផ្លូវចិត្តដល់អ្នកដាក់ពាក្យសុំគឺជាការស្លាប់បងប្រុសរបស់គាត់។ បើគ្មានទំនាក់ទំនងនេះទេ ព្យសនកម្មរបស់គាត់មិនអាចបណ្តាលមកពីបទឧក្រិដ្ឋនេះបានឡើយ។ ចំណងហេតុ និងបច្ច័យនៅក្នុងករណីនេះជាទម្រង់សង្ខេបគឺជា៖ បទឧក្រិដ្ឋរបស់ជនត្រូវចោទ ការស្លាប់បងប្រុសគាត់ និងព្យសនកម្មរបស់អ្នកដាក់ពាក្យសុំ។

៧. ចំណុចនេះមិនបានផ្ទុយនឹងសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះទេ ដែលនៅក្នុងមាត្រា៣.២គ គ្រាន់តែចែងថា ព្យសនកម្មផ្លូវចិត្តអាចរួមមានការស្លាប់សាច់ញាតិជិតស្និទ្ធដែលជាជនរងគ្រោះនៃបទឧក្រិដ្ឋទាំងនេះ តែមាត្រានេះមិនបានសំដៅដល់ទំនាក់ទំនងហេតុ និងបច្ច័យរវាងព្យសនកម្ម និងបទឧក្រិដ្ឋទេ។ ទោះជាយ៉ាងណាក្តី សេចក្តីណែនាំអនុវត្តគ្រាន់តែជាសេចក្តីណែនាំ ដែលពុំមានលក្ខណៈសម្បត្តិជាវិធាន កុំថាឡើយដល់ទៅជាច្បាប់នោះ។

---

[៧] សូមមើលនិយមន័យនៃពាក្យ "direct" ("ដោយផ្ទាល់") នៅក្នុងវចនានុក្រម Oxford Online Dictionary ថា "ពុំមានកត្តា ឬអន្តរការីនានាធ្វើអន្តរាគមន៍"។

៨. សហចៅក្រមស៊ើបអង្កេតទទួលស្គាល់ថា គាត់បានទទួលយកអ្នកដាក់ពាក្យសុំជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២[៨] តែវាច្បាស់ណាស់នៅក្នុងសេចក្តីសម្រេចនោះ (ដែលត្រូវបានធ្វើឡើងក្រោមសម្ពាធដ៏ធ្ងន់ធ្ងរនៃពេលវេលា ក្នុងការនាំយកសំណុំរឿង០០២ ទៅកាន់សវនាការ) ថា លក្ខខណ្ឌតម្រូវនៃភាពដោយផ្ទាល់នៃទំនាក់ទំនងហេតុ និងបច្ច័យ មិនត្រូវបានពិនិត្យពិច័យឱ្យបានស៊ីជម្រៅនាពេលនោះទេ។ នៅក្នុងដីកាសម្រេចនោះ ត្រង់ជំពូកដែលមានចំណងជើងថា "ទំនាក់ទំនងហេតុ និងបច្ច័យរវាងព្យសនកម្ម និងឧក្រិដ្ឋកម្មទាំងឡាយដែលបានចោទប្រកាន់លើជនត្រូវចោទ" លើកឡើង (ត្រង់កថាខណ្ឌ១៥) ថា "អ្នកដាក់ពាក្យសុំចាំបាច់ត្រូវតែបង្ហាញពីព្យសនកម្មដែលកើតឡើងដោយផ្ទាល់ពីអង្គហេតុដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម" តែមិនបានពន្យល់ពីលក្ខខណ្ឌតម្រូវនៃពាក្យថា "ដោយផ្ទាល់" ទេ។ នៅចុងបញ្ចប់នៃជំពូកនេះ (ត្រង់កថាខណ្ឌ១៨) ដែលបានបង្ហាញពីលក្ខខណ្ឌតម្រូវថា "ព្យសនកម្មដែលបណ្តាលមកពីអង្គហេតុណាមួយដែលបានបើកការស៊ើបសួរហើយ" ក៏ទំនងជាបង្ហាញថា ទស្សនទាននេះ បើទោះជាមានចំណងជើងបែបនេះក្តី មិនពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវនៃភាពដោយផ្ទាល់នៃហេតុ និងបច្ច័យទេ។

ទោះជាយ៉ាងណាក្តី ការពិចារណាដែលនាំឱ្យចេញសេចក្តីសម្រេចនេះ មិនចងកាតព្វកិច្ចទេ ហើយក៏មិនអាចរារាំងមិនឱ្យសហចៅក្រមស៊ើបអង្កេត (បច្ចុប្បន្ន) អនុវត្តវិធានតាមវិធីមួយដែលនាពេលនេះយល់ថាជាការត្រឹមត្រូវដែរ។

៩. សហចៅក្រមស៊ើបអង្កេតក៏ទទួលស្គាល់ផងដែរថា នៅក្នុងសាលក្រមលើសំណុំរឿង០០១ អង្គជំនុំជម្រះសាលាដំបូងបានទទួលយកអ្នកដាក់ពាក្យសុំជាដើមបណ្តឹងរដ្ឋប្បវេណី តែ ស.ច.ស មិនអាចអនុវត្តតាមសំអាងហេតុ (ត្រង់កថាខណ្ឌ៦៥០ នៃសាលក្រម) ដែលថាអ្នកដាក់ពាក្យសុំបានបង្ហាញថា "ព្យសនកម្មរបស់គាត់ជាផលវិបាកដោយផ្ទាល់នៃបទឧក្រិដ្ឋ ..." បានទេ។

---

[៨] ឯកសារលេខ D404: ដីកាសម្រេចស្តីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានអាស័យដ្ឋាននៅក្រៅព្រះរាជាណាចក្រកម្ពុជា។

ការយោងនៅក្នុងសាលក្រម (នៅក្នុងជើងទំព័រ១០៧៥) ទៅដល់មាត្រា២ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង គឺគ្មានការសម្រេចអ្វីទេ ដោយសារថា មាត្រានេះត្រឹមតែចែងថា អ្នកដែលបាន "រងព្យសនកម្មផ្ទាល់ខ្លួន ដោយសារបទល្មើសនោះដោយផ្ទាល់" អាចធ្វើបណ្តឹងរដ្ឋប្បវេណីបាន តែមិនបានពន្យល់ពីលក្ខខណ្ឌតម្រូវនៃពាក្យថា "ដោយផ្ទាល់" ទេ។

ប្រការនេះក៏អនុវត្តដូចគ្នាចំពោះការដកស្រង់នូវមាត្រា១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៦៤ ដែរ។

ត្រង់ប្រការនេះ (ក្នុងជើងទំព័រដដែល) ការយោងទៅដល់ "គោលការណ៍មូលដ្ឋាន និងការណែនាំស្តីពីសិទ្ធិទទួលបានដំណោះស្រាយ និងសំណងសម្រាប់ជនរងគ្រោះ ។ល។" (ក្នុងកថាខណ្ឌ ៨) ពិតជាបានរួមបញ្ចូលសមាជិកគ្រួសារផ្ទាល់ ឬអ្នកក្នុងបន្ទុកមែន តែលុះត្រាតែអ្នកទាំងនោះបានទទួលរងព្យសនកម្ម "ក្នុងការជួយជនរងគ្រោះ" ដែលជាករណីនេះមិនមែនជាករណីរបស់អ្នកដាក់ពាក្យសុំដែលក្រោយពេលបងប្រុសគាត់បានស្លាប់ ២ ឆ្នាំមកហើយនៅកម្ពុជា ទើបគាត់បានទទួលដំណឹងនេះពីសារព័ត៌មានមួយនៅប្រទេសនូវ៉ែលហ្សេឡង់នោះ។

**អាស្រ័យនៅតាមសំអាងហេតុទាំងនេះ សហចៅក្រមស៊ើបអង្កេតសម្រេចដូចតទៅ៖**

**ប្រកាសថា** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានលេខសម្គាល់ VU 11-VSS-00002 **(D11/2)** មិនត្រូវបានទទួលយកទេ និងប្រកាសបន្ថែមទៀតថា ដោយសារព័ត៌មាននៅក្នុងពាក្យសុំនេះទាក់ទិននឹងអង្គហេតុដែលបានកើតឡើងពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ រហូតដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ នៅលើទឹកដីកម្ពុជាប្រជាធិបតេយ្យ ព័ត៌មានទាំងនោះនឹងត្រូវដាក់បញ្ចូលក្នុងសំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អវតក-កសចស ជាពាក្យបណ្តឹង។

**បដិសេធ**ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០៣ និងសំណើសុំដទៃទៀតពាក់ព័ន្ធនឹងពាក្យសុំនេះ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១១

**សហចៅក្រមស៊ើបអង្កេត**
**Co-Investigating Judges**
**Co-juges d'instruction**

ហត្ថលេខា និង ត្រា

**យូ ប៊ុនឡេង**

បណ្ឌិត **Siegfried BLUNK**